AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com




CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com

# ច្បាប់ក្រមង៉ុយ

- ច្បាប់ល្បើកថ្មី
- ច្បាប់កេរកាលថ្មី
- សេចក្តីរំលឹកដាស់តឿន
- ពាក្យកាព្យប្រដៅជនប្រុសស្រី

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



## អារម្ភកថា

ច្បាប់ក្រមង៉ុយនេះកាលបោះពុម្ពលើកមុនៗ ចែកចេញជាបីសៀវភៅ គឺសៀវភៅទី១ មានច្បាប់ល្បើកថ្មី និងកេរកាលថ្មី. ទី២ សេចក្តីដាស់តឿន និងទី៣ពាក្យកាព្យប្រដៅជនប្រុសស្រី ។ នៅគ្រាបោះពុម្ពលើកទី៦នេះ ដោយនិយមតាមសេចក្តីស្នើពីមជ្ឈដ្ឋានអ្នកសិក្សាជាច្រើននាក់ដែលសុំអោយយើងផ្តុំគ្នាយកច្បាប់នេះមករួមគ្នាជាសៀវភៅមួយ ត្បិតទុកអោយនៅដោយឡែកៗជាកូនសៀវភៅតូចៗនោះនាំអោយរប៉ាត់រប៉ាយ ពិបាកថែរទាំ ។ យោបល់នេះត្រឹមត្រូវណាស់ ទើបយើងសម្រេចប្រមូលផ្តុំបានជាសៀវភៅមួយនេះឡើង ។

ចំពោះពាក្យពេចន៍ កាព្យឃ្លោងទាំងអស់នៅក្នុងច្បាប់ទាំងប៉ុន្មាននេះ យើងគ្មានប៉ះពាល់កែប្រែសោះឡើយ សម្រួលតែរបៀបតម្រៀបឃ្លាល្បះអោយមានលំនាំទៅតាមបែបកាព្យត្រឹមត្រូវប៉ុណ្ណោះ ។

គោលបំណងធំរបស់យើងខ្ញុំមួយទៀត គឺការចង់រក្សាស្នាដៃដ៏មានតម្លៃនៃលោកតាកវី **ភិរម្យង៉ុយ ឬក្រមង៉ុយ** ព្រោះពាក្យសំដីរបស់លោកក្នុងនេះទាំងអស់សុទ្ធតែមានន័យទូលំទូលាយ ហើយប្រកបដោយខ្លឹមសារល្អណាស់មិនចេះហួសសម័យកាលនោះផង តាំងពីគ្រាលោកសរសេររហូតសព្វថ្ងៃនៅតែមានន័យត្រូវគួរនិងធ្វើគតិទូន្មានខ្លួនបាន ។

ឆ្លៀតឱកាសនេះ ពុទ្ធសាសនបណ្ឌិតសុំសម្តែងគារវកិច្ចដ៏ជ្រាលជ្រៅចំពោះវិញ្ញាណក្ខន្ធនៃលោកកវីដ៏ឆ្នើមនេះផង ។

ភ្នំពេញ ខែ សីហា ឆ្នាំ ១៩៧២

**ពុទ្ធសាសនបណ្ឌិត្យ**

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



# ពាក្យកាព្យ
# ប្រដៅជនប្រុសស្រី

ខ្ញុំសូមបង្គំព្រះសម្មា
ចំរើនកម្មដ្ឋានក្រោមពោធិ៍ម្លប់
ព្រះចមចក្រពិននិរន្តឫទ្ធិ
សូមថ្វាយបង្គំព្រះករុណា
ឱនកាយបង្គំប្រណម្យនឹក
ធ្លាប់ជ្រកទីពឹងព្រះបារមី
សរណគមន៍បីអោយប្រតិបត្តិ
រូបយើងសព្វថ្ងៃថ្លៃមិនថោក
ផ្លូវប្រែតនរកទៅញីកញយ
គួរគិតសង្វេបឃាត់សង្ខារ
ជម្ពូទ្វីបនេះធំបំផុត
សត្វស្លាប់តាមកម្មមិនចាំចាស់
រូបំ អនិច្ចំ   អនត្តា
តាមដានដរាបបាបអោយផល
ខ្លះមកអំពីប្រែតតិរច្ឆាន
វេរាតាមរកបានឃើញមុខ
អ្នកធ្លាប់ទៅរងនរកប្រែត
ទឹកក្តៅខ្លះដែកទៅដេកត្រាំ
មកកើតជាមនុស្សស្ថានកណ្តាល
ប្រពន្ធកូនគេនៅតែលួច
ស្រាវីតតែផឹកអោយស្រវឹង
ស្រេកឃ្លានបំពានធ្វើលើច្បាប់
ពិតមែនជាមិនឮព្រះឱស្ឋ

សម្ពុទ្ធណា១ក្នុងត្រៃភព
ខ្ញុំសូមគោរពនមស្សការ ។
ជាម្ចាស់ជីវិតលើសិរសា
សូមទ្រង់មេត្តាប្រោសប្រណី ។
សូមកើនរំលឹករាស្ត្រប្រុសស្រី
អោយរៀនបាលីទៅបរលោក ។
កំចាយកំចាត់ក្តីទុក្ខសោក
បានមកភពភាន់ទាន់សាសនា ។
គួរកុំបណ្តោយតាមតណ្ហា
សង្ឃឹមព្រះសិអារ្យនឹងមកត្រាស់ ។
មួយម៉ឺនយោជន៍គត់ដំណែលព្រះ
អាយុខ្លីណាស់ក្រាស់អកុសល ។
កើតរូបកាលណាកម្មតាមដល់
បាបខ្លះសេសសល់ពីនរក ។
ខ្លះមកពីស្ថានសួគ៌សោយសុខ
ចុះមករងទុក្ខទទួលកម្ម ។
ដើមហេតុពីព្រោះដាច់សីល៥
រាប់លានកោដិឆ្នាំទំរាំរួច ។
មិនរាងមិនចាលដល់តិចតួច
សត្វធំសត្វតូចរីតសម្លាប់ ។
គុណទោសមិនដឹងប្រឹងចាក់កាប់
មិនស្តាប់ពុទ្ធដីកាព្រះអង្គផ្តាំ ។
ព្រះសង្ឃទ្រង់ប្រោសអោយសីល៥

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ទទួលរំពេចភ្លេចមិនចាំ ប្រព្រឹត្តសាងកម្មមិនព្រមលែង ។
កើតមកពូជពង្សពេញជាមនុស្ស សេចក្តីត្រូវខុសចាំជាក់ស្តែង
សម្លាប់រូបសត្វឥតគិតក្រែង បំពេញរូបឯងអោយធំធាត់ ។
សម្លាប់មិនថាសត្វឈ្មោលញី យកសាច់មកស៊ីអោយឆ្ងាញ់មាត់
ទទួលសីលភ្លើធ្វើអោយភ្លាត់ លក់សត្វអោយភ្លាត់មេព្រាត់កូន ។
ព្រាត់គូកំសត់វដ្តសង្សារ ដូចលក់ជីតាលក់ជីដូន
ពុំនោះលក់បងបំបែកប្អូន ងងឹតឈឹងសូន្យមើលមិនយល់ ។
ខ្លះទៅនរកមិនទាន់មក ខ្លះឃ្លាតទៅជ្រកពួកអសុរ
ជវនសង្ខារឡប់វិលវល់ អំពល់តែកើតស្លាប់កើតស្លាប់ ។
កម្មកិតតាកខ្លួនមិនដែលឃ្លាត គ្រប់ប្រាំរយជាតិមិនដែលឆាប់
សត្វជ្រូកមាន់ទាគេចាក់កាប់ សម្រាប់គេស៊ីជាអាហារ ។
សត្វគោក្របីដំរីសេះ គេជិះគេទឹមជាធម្មតា
គេកាប់លក់សាច់ផ្តាច់សង្សារ រកចិត្តមេត្តាករុណាគ្មាន ។
រូបខន្ធរលត់រលាយទៅ សល់នៅសង្ខារនឹងវិញ្ញាណ
វេទនាសញ្ញានឹកស្រេកឃ្លាន សន្និដ្ឋានថាដូចអ្នកមានគុណ ។
សត្វញីសត្វឈ្មោលអន្ទោលទុក្ខ អាពុកឬម្តាយពីជាតិមុន
ជាតិមកពីរងទោសទុក្ខធ្ងន់ ក្រែងស៊ុនទៅលើសាច់ញាតិឯង ។
ជ្រូកគោក្របីនៅតូចស្មោរ គេក្រៀកវះក្រៀវឃើញជាក់ស្តែង
បើគិតអោយសព្វគ្រប់កន្លែង ជួនក្រែងជាតិមនុស្សមកជាសត្វ ។
អ្នកពឹងនឹងអ្នកធ្វើដៃដល់ ចៅក្រមអកុសលជំនុំកាត់
បញ្ជីទាំងពីឈ្មោះមិនបាត់ គេចាត់ធ្វើទោសទាំងអស់គ្នា ។
មិនមានអ្នកណាធ្ងន់ស្រាល យមបាលវះក្រៀវគ្រប់វេលា
មានលោកយករាជរាជសភា ជំនុំគិតគ្នាមើលបញ្ជី ។
បញ្ជូនអ្នកធ្វើចុះនរក ជំនុំឃុំទុក្ខអ្នកទិញស៊ី
ទិញសត្វស្លាប់រស់ទោះឈ្មោលញី ទាំងពីរចំណែកចំណាំមុខ ។
អ្នកមួយទិញស៊ីមិនរួចខ្លួន ត្រឹមងត្រីអួនយួនដូរលក់
អណ្តែងក្រាញ់ឆ្តោរជៀបរស់ផ្ទុក ចង់ទិញស្មោរជ្រក់ទៅតថ្លៃ ។
ឃើញច្បាស់ជារស់មិនងាប់ អង្គុយបង្គាប់អោយយួនវៃ
រកខ្យល់ច្រឡោតដោយញ៉ៅរដៃ ឃើញក្បែយស្រាប់ៗមិនទិញយក ។

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



អានេះបន្ទរលែងមិនបាន ត្រូវច្រំធាក់ច្រានអោយជ្រុលជ្រក
ទម្លាក់អោយជ្រៅរងទុក្ខសោក លៃលកអ្នកទោសរឿងអ្នកទិញ ។
អ្នកទៅឃើញត្រីនៅបម្រះ វេទនាចិត្តណាស់ប្រាស់ដើរចេញ
អ្នកនេះត្រូវលែងអោយទៅវិញ មានសៃហ្វលិញគិញក្នុងនរក ។
អោយជូនខ្លាចក្រែងវង្វេងផ្លូវ ត្រួតមើលខុសត្រូវគ្រប់ភូមិស្រុក
បើកក្រាំងសៀវភៅកត់ឈ្មោះទុក បញ្ជីពីរមុខបាបនិងបុណ្យ ។
ប្រគល់យមរាជយមរាជ្ញបាល ដាក់ស្រាលដោយស្រាលធ្ងន់ដោយធ្ងន់
អ្នកសាងមគ្គផលស្គាល់ទោសគុណ ទៅសោយសុខមុនតាមទុនទាន ។
អ្នកសាងធុនទាបភាពអកុសល មិនចង់បានផលសួគ៌និព្វាន
ប្រព្រឹត្តអាក្រក់រកល្អគ្មាន មិនហ៊ានកាន់សីលថាខ្លាចដាច់ ។
មិច្ឆាទិដ្ឋិចូលពេញទី បញ្ជីសម្រាំងតាំងសម្រេច
ចុះវង្សអាជីវកត្តកស៊ីអាចម៍ ព្រោះពោលបង្កាច់ព្រះពុទ្ធដីកា ។
វិធីទុច្ចរិតមានគ្រប់យ៉ាង ទានសីលមិនសាងអាងផឹកស្រា
ឮលោកសំដែងធម៌ទេសនា ពីរោះពិស្តារមិនដឹងស្តាប់ ។
អស់យើងគួរស្តាយជាតិកំណើត សំណាងមកកើតក្នុងភទ្ទកប្ប
អគារវិន័យព្រះប្រញ្ញត្ត ជាឫសគល់ច្បាប់គួររក្សា ។
សីល៥ចងចាំអោយប្រាកដ កុសលកម្មបថ ១០ ប្រការ
កុំឈ្លោះប្រកែកពីធម៌អាថ៌ ប្រកាន់សាសនាអោយប្រាកដ ។
កើតមកជាមនុស្សមានសខ្មៅ មានប្រាជ្ញមានខ្លៅមានក្រខ្សត់
មានខ្លាំងមានខ្សោយដោយបែបបទ សន្មតថាល្អក៏មិនបាន ។
ជម្ពូទ្វីបនេះមនុស្សកម្មក្រាស់ ព្រះពុទ្ធតែងត្រាស់មិនដែលខាន
ហេតុនេះមហាជនទាំងប៉ុន្មាន សម្រាកសម្រាន្តសម្រួលចិត្ត ។
បំណាច់សម្តេចព្រះទ្រង់ញាណ កាលហៀបនិព្វានមានគីរិត
ផ្តាំមហាអានន្ទអោយអាណិត អានុជអ្នកប្រើតប្រោសសត្វផង ។
សត្វផុងទៅក្នុងជ្រោះជ្រាំជ្រៅ តថាគតនៅនាំចំឡង
ដាក់ដល់និព្វានអស់ហ្មត់ហ្មង រួចពីចំណងវដ្តសង្សារ ។
នៅសល់សង្ស័យសត្វខាងក្រោយ ននួអើយទុកអោយព្រះសិអារ្យ
អាណិតសត្វណាស់ណាអ្នកណា តថាគតជិតនិព្វានហើយ ។
ព្រះឱស្ឋព្រះអង្គល្ហមស្រណោះ សម្បុរសទាំងអស់កុំកណ្តើយ

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ប្រះខ្នងដេកលើកន្ទេលខ្មៀយ កុំស្មៀមមាត់ឡើយរំលឹកគុណ ។
ខ្លួនខ្ញុំកំណើតរាស្ត្រអ្នកស្រែ ខូចខិលខ្ជិលដែរពីកាលមុន
កាលមោហ៍បាំងបិទងងឹតស៊ុន ធ្វើបាបនិងបុណ្យទម្ងន់ស្មើ ។
មិនស្មោះតែរូចចតុរាបាយ អស់លោកទាំងឡាយកុំសរសើរ
ខ្ញុំជូនដំណឹងតាមដំណើរ ព្រោះខ្ញុំគ្រាក់បើជាងអ្នកល្ងង់ ។
ជាតិក្រោយកុំអោយខ្ញុំល្ងីល្ងើ ជាតិនេះចាស់ស្ទើរខ្ញុំប្រឹងស្ទង់
ប្រឹងស្ទុះអោយរួចពីអន្លង់ ភ័យភិតខ្លាចផុងទៅក្នុងភក់ ។
ក្នុងភពសង្សារខ្ញុំសង្ស័យ សព្វថ្ងៃខ្ញុំភ័យខ្លាចរនក
ម្យ៉ាងទៀតខ្ពើមជាតិអាជីវក ជាតិល្មោភហួបល្មក់ព្រោះល្មិលគុណ ។
ច្រើនល្មើសបន្ទូលបន្ទោលព្រះ ខ្ញុំភ័យខ្ញុំណាស់ក្រែងខ្ញុំស៊ុន
ខ្ញុំសូមស្មាលាទោសពីមុន សូមបុណ្យជួយបាំងបាបអោយបាត់ ។
អោយបានទាន់តួព្រះសិអារ្យ អោយបែកប្រាជ្ញាឆ្លាតបរមត្ថ
ព្រះអង្គទេសនាទ្រង់ប្រោសសត្វ សូមលុះអរហត្តដូចបំណង ។
បំណាច់ខ្ញុំផ្សាយច្បាប់រលឹក អស់លោកជួយនឹកសច្ចាផ្សង
ធ្វើបុណ្យចែកផលដល់ខ្ញុំផង នឹកឈ្មោះម្តងដូចធម្មតា
សប្បុរសប្រុសស្រីគប្បីស្តាប់ ឈ្មោះច្បាប់កន្លងព្រះឱង្ការ
ឱកាសអោយគិតប្រឹតប្រាជ្ញា ទាន់ព្រះសិអារ្យទាំងប្រុសស្រី ។
កុំរៀនព្រហើនប្រហែសធ្វេស កើតក្នុងប្រទេសរាជបុរី
អោយមានបារម្ភភ្ជាក់ស្មារតី សីលប្រាំ-ប្រាំបីខំសិក្សា ។
ជាតិមនុស្សជាន់ខ្ពស់ពីរបុរាណ គេបានជួយដាក់ឃើញភក្រ្តា
បានគ្រង់រងគ្រាប់ព្រះពុទ្ធដីកា បានលុះសោតាអរហត្តហោះ ។
យើងទាន់តែត្រឹមពាក្យបណ្តាំ បណ្តូលសីលប្រាំជាកេរ្តិ៍កោះ
កិច្ចការកងកម្មចាំមិនអស់ របស់បួសគល់គួររក្សា ។
នេះចប់ចំណែកខាងឧបាសក កុំធ្វើអាក្រក់រាល់រូបបា
រំពឹងក្រែងជួបព្រះសិអារ្យ នមស្សការគោរពរំលឹកគុណ ។
ព្រះចមចក្រពង្សមុនីនាថ កំពូលផុតជាតិជាងមហាជន
ទ្រង់សោយសម្បត្តិសម្បើមបុណ្យ សម្បូរលុនលុបលោកា ។
លោកកីយដឹងហើយគួរកោតខ្លាច ទ្រង់មានអំណាចព្រះចេស្តា
គួរស្តាប់ព្រះរាជឱង្ការ បន្ទូលត្រួតត្រាគួរគ្រង់គ្រាប់ ។

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ព្រះទ័យទ្រង់ត្រេកស្រឡាញ់សង្ឃ ប្រមាណសែនអង្គក្នុងភទ្ទកប្ប
ព្រះពុទ្ធទ្រង់ប្រើតប្រាមប្រញ្ញត្ត ឈ្មោះច្បាប់បាដិមោក្ខសំវរសីល ។
ចែកចេញជាកងសិក្ខាបទ កំណត់ពីររយម្ភៃប្រាំពីរ
មិនអោយមានមោះហ្មងមន្ទិល អ្នកបួសកុំខ្ជិលកាន់អោយខ្ជាប់ ។
បាណាអទិន្នាជាបឋម ជាតិរូបទៀតផ្សំត្រូវជាដប់
លោកសង្ឃឥឡូវកាន់មិនសព្វ កាន់ក្នុងបន្ទប់លាយបន្លំ ។
បន្ទិចលុយកាក់លាក់សម្ងាត់ ទោសត្រូវអាបត្តិលាកសំងំ
បាសកផ្ញើទានគ្មានអារម្មណ៍ សន្សំតែទ្រព្យក្តៅក្រហាយ ។
ប្រសិនបើកាន់ច្បាប់ព្រះពុទ្ធ មិនមានធម្មសុត្តិមហានិកាយ
បើចេះខ្លាចក្រែងមិនក្លែងក្លាយ សមសុខសប្បាយមិនទាស់គ្នា ។
លោកសង្ឃគ្រប់វត្តមានតូចធំ សង្ឃខ្លះខ្ជិលខូចសង្ឃខ្លះជា
បរិស័ទថ្កោលទោសគ្រូឧបជ្ឈាយ៍ មានពាក្យនិន្ទាតែរាល់វត្ត ។
បាដិមោក្ខពីររយម្ភៃប្រាំពីរ អ្នកល្ងង់ថាខ្ជិលចាំមិនស្ទាត់
កងបាចិត្តិយនឹងទុក្កដ ចូលមាត់ចូលកមិនដឹងខ្លួន ។
កងបាចិត្តិយកៅសិបពីរ និស្សគ្គនយ៍សាមសិបបារាជិបួន
បេកចេះហើយចាំអោយមាំមួន ល្អបរិសុទ្ធសួនមិនសាយសុស ។
ប៉ុន្តែសិក្ខាមិនស្រូវចាំ ចំណាំត្រង់ណោះចោលត្រង់ណោះ
ត្រង់ណាដែលដឹងជាខ្លួនខុស ហ៊ានឈ្លោះពីព្រោះគេមិនដឹង ។
សង្ឃាទិសេសប្រហែលបាន ដប់បីសន្ធានប្រមាណថ្លឹង
បើធាប់សង្រួមអោយយ៉ាងតឹង មិនអមមិនខឹងមិនខាតខុស ។
ឥន្ទ្រីយ៍ប្រាំមួយនាំអោយភ្លាត់ បាចិត្តិយ៍ទុក្កដលាយចំរុះ
ឥន្ទ្រីយ៍ត្រចៀកភ្នែកច្រមុះ ភ្នែកមើលណោះណោះឃើញសុសសាយ ។
សោតិន្ទ្រិយោស្តូរតិចខ្លាំង ចក្ខុន្ទ្រិយំឃើញជិតឆ្ងាយ
ជិវ្ហិន្ទ្រិយាពោលនាយអាយ សើចលេងសប្បាយចំអន់គ្នា ។
បរិស័ទអាបត្តិទុក្កដញឹក បារាជិកច្រើនណាស់តែឧបជ្ឈាយ៍
ទ្រព្យក្នុងសំបាច់សំបូណ៌ហៀរ ត្រូវទោសអទិន្នាគរុភ័ណ្ឌ ។
ទ្រព្យសង្ឃជាដើមគឺចំណាំ អវហារម្ភៃប្រាំចាំត្អែរគ្នាន់
ឱបទុកខ្ទះខ្មែងក្រែងមិនគ្រាន់ អវហារប្រាំជាន់បារាជិក ។
ម៉្យាងទៀតទ្រព្យសង្ឃក្នុងចំណែក កិបទុកមិនចែកអោយលោកភិក្ខុ

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



គ្រឿងយារជីវិកកាលិក ទុកខួបល្ងាចព្រឹកម៉ៅតែឯង ។
ម៉្យាងព្រទ្យគេហែចូលវិហារ បាសកបូជាដល់គម្តែង
គេវេរបាលីមានខ្លីវែង គេតែងនឹងថាសង្ឃស្ស ។
ប្រកាសប្រគេនជំនុំសង្ឃ ចំពោះគ្រប់អង្គថាទេម:
លោកសង្ឃសាធុគ្មានសល់ម្នាក់ សង្ឃរាជទុកដាក់មិនចែកចាយ ។
ខ្ញុំបាទចែងតាមខ្ញុំចេះចាំ អវហារម្តេប្រាំបែកបរិយាយ
នេះសុទ្ធតែសីលផ្ទុសអន្តរាយ លោកសង្ឃទាំងឡាយកុំប្រព្រិត្ត ។
ពីព្រោះឥន្ទ្រីយ៍ទាំង៦ លោកណាមិនព្រួយមិនប្រុងគិត
លោកភោមោហោបាំងងងឹត សិស្សមានគំនិតមិនហ៊ានថា ។
សូមទានសន្តោសសម្តែងច្បាប់ ព្រះសង្ឃកុំចាប់ចងទោសា
ខ្លួនខ្ញុំសូមសុំបវារណា ប្រោសប្រាណមេត្តាគ្រប់សណ្ឋានសង្ឃ។
ខ្ញុំមិនមានពោលពាក្យបង្អាច់ ខ្លាចសីលលោកដាច់ខ្ញុំតម្រង់
តម្រូវតែតាមច្បាប់ព្រះអង្គ ព្រះឱស្ឋត្រឹមត្រង់ត្រូវមាត្រា ។
កាលអង្គសម្តេចព្រះចមភព បន្ទូលប្រារព្ធគ្រប់ប្រការ
ប្រកាសប្រាកដបទសិក្ខា ប្រញូប្តប្តេជ្ញាមហាបរិស័ទ ។
ភិក្ខុភិក្ខុនីអស់អរហន្ត អានន្ទមិនទាន់បានអរហត្ត
ព្រះធម៌វិន័យកុំអោយបាត់ ប្រយ័ត្នអោយគង់ប្រយោជន៍យូរ ។
ក្រោយនោះព្រះអង្គចូលនិព្វាន្ត អរហន្តហោះធ្យានមានជាគ្រូ
មិនមានអក្ខរាណាដាក់ទូ ទេសនាបង្ហូរពីព្រះឱស្ឋ ។
ព្រះអគ្គសាវ័កគ្រប់ព្រះអង្គ ព្រះទ័យស្រោចស្រង់ទ្រង់សន្តោស
សំដែងធម៌អាថ៌មេត្តាប្រោស បាបបុណ្យគុណទោសនឹងសីលទាន ។
ឈ្វេងយល់ថាធម៌នឹងសូន្យស្ងាត់ អរហត្តអរហត្តចូលនិព្វាន
សង្ឃសេក្ខបុគ្គលមិនទ្រង់ញាណ មិនមានអក្ខរាណាតែងទុក ។
ព្រះធម៌ប្រាំបីម៉ឺនបួនពាន់ ស្រេចលើណានន្ទចាំទំនុក
ដំណែលព្រះអង្គដឹងគ្រប់មុខ ជម្រុកធម៌អាថ៌មហាអានន្ទ ។
ជាព្រះអនុជអាណិតសត្វ ក្រែងបាត់បិដកមិនគ្រប់គ្រាន់
ព្រះធម៌ប្រាំបីម៉ឺនបួនពាន់ គ្មែនគ្មាន់ខ្វះខ្នែងចាត់ចែងចារ ។
ចេះចប់អភិធម្មចាំរហូត វិន័យព្រះសូត្រ ៥ ប្រការ
ប្រកាសអស់អង្គអរហន្តា បិដកឯណាជាឫសគល់ ។

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



បរមត្ថព្រះសូត្រអានទ្ធចាំ
អរហត្តទាំងអស់កើតរវល់
ព្រះបាទអជាតៈសត្រូវ
សម្មតិអោយឈ្មោះហៅក្សត្រា
និយាយអោយដឹងដើមកំណើត
បកប្រែបាលីសេចក្តីពិត
ទសជាតក៍ទាំង ១០ មានគ្រប់វត្ត
ព្រះធម៌សូត្រមន្ត ឬសូត្រដារ
ចំណេះចំណាំចាំដោយខ្លួន
ហ៊ានក្នាល់ព្រោះអាងឃើញនឹងភ្នែក
ប្រកាន់តែខាងខុសរហូត
អាងចេះតែកកាប៉ុណ្ណឹង
ក្តៅណាស់ពីរឿងយោជាយោ៉
ថាធ្លាប់យោនាពីខ្មោចឪ
អ្នកម្ខាងអាងស្រះតួប្រាំបី
ផ្សំតួរមេសូត្រប្រឹងប្រែងប្រឹត
អ្នកបួសគ្រប់វត្តគ្រប់នគរ
បើសជើងមរាប់ស្នូស្នា
កុំល្ងង់ទាល់ងាប់ធ្លាប់មិនដឹង
ខដាក់ជើងមពីបុរាណ
ជាតិរាស្ត្រចាស់ក្មេងកុំចិត្តខ្លាំង
ដើមហេតុអំពីព្រះករុណា
ទ្រង់ចាំទំនៀមពីបុរាណ
បំណាច់ធ្វើស្តេចគ្រងផែនដី
ព្រះកាយពលមិនរវល់រែក
ចូលទៃទនបន្ទំទីបន្ទប់
មេត្តាប្រោសប្រាណអ្នកមានស័ក្តិ
ទ្រង់ត្រួតស្ត្រីស្នំស្រីង្គារ
ព្រះទ័យមេត្តាសព្វមនុស្សសត្វ

វិន័យទាំង ៥ ឧបាលិយល់
អំពល់អំពីរឿងធម៌អាថ៌ ។
ជួយគិតតម្រូវព្រះសាសនា
ព្រោះព្រះមហាក្សត្រិយ៍ចូលគំនិត ។
កកើតអក្ខរាចារស្ទឹករឹត
ពិនិត្យត្រឹមត្រូវតាមពុទ្ធដីកា ។
ប្រែត្រូវប្រាកដព្រះគាថា
អ្នករៀនអក្ខរាពីរចំណែក ។
ខ្លះរៀនមានក្បួនចាស់ចារចែក
កើតឈ្លោះប្រកែកប្រកួតខឹង ។
មិនរៀនមេសូត្រអោយចេះដឹង
ខំប្រឹងចំអើតអួតខ្លួនត្រូវ ។
តំឡើងភ្នែកស្លោមុខក្រញូវ
ឥឡូវយោណាមិនសុខចិត្ត ។
អោយដឹងបាលីជាក៏រឹត
ព្រោះត្បិតអោយត្រឹមត្រូវមាត្រា ។
សដាក់ជើងលរាប់សួស្លា
អ្នកមានប្រាជ្ញាល្មមស្តាប់បាន ។
បើខឹងខ្ញុំឃាត់ថាអោយខាន
ក្មេងតូចរប៉ុន្មានស្គាល់ខ្នា ។
គួរខ្មាសបារាំងអ្នករាជការ
អោយសាងសាលាប្រែបាលី ។
ហើយបានជំនុំព្រមកុង្សីយ
ទិសទាំងប្រាំបីរំពៃគ្រប់ ។
ព្រះទ័យរំលែកទាំងថ្ងៃយប់
បន្ទូលមិនឈប់រាល់វេលា ។
ព្រះទានលុយកាក់គ្រប់ភ្នាក់ងារ
ក្រែងគ្រូនរងារមិនបានសុខ ។
សោយរាជសម្បត្តិសម្បើមស្តុក

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ព្រះកាយប្រកបគង់ស្រណុក ព្រះទ័យវិតក្កជាធម្មតា ។
មួយព្រួយនឹងឱបព្រះនគរ ពីរគ្រួយនឹងពារព្រះសាសនា
បីត្រួតលោកសង្ឃកាន់សិក្ខា សង្រួមកិរិយាមិនបរិសុទ្ធ ។
នឿយណាស់ព្រះនេត្រព្រះកាណ៌ា ព្រះឱស្ឋត្រួតត្រាច្រើនបំផុត
ដាស់តឿនបំភ័យពួកកុលបុត្រ អោយប្រុងលំឱតសង្រួមកាយ ។
បានចេញប្រកាសដាស់ប្រាកដ ប្រគេនគ្រប់វត្តទោះជិតឆ្ងាយ
លោកសង្ឃមិនត្រូវស្រើបសប្បាយ អស់ល្បែងទាំងឡាយគ្រប់ចំពូក ។
មិនត្រូវចំពោះស្តាប់តន្ត្រី កុំបីមើលរាំវានាំភ្លូក
កុំដើរភ្លើៗមើលអុំទូក អ្នកបួសធ្វើលោកមិនត្រូវការ ។
បើមានត្រូវកិច្ចដើរយប់ថ្ងៃ សង្ឃបងនិស្ស័យចាស់វស្សា
កុំដើរទីមស្មាទៅណាៗ អ្នកចេះសិក្ខាគេទាស់ភ្នែក ។
លោកនេនកុំសុំលុយមិនចាយ បិណ្ឌបាតតែបាយម្នាក់ ១ វែក
គ្រឿងម្ហូបចំណីបាសកចែក កុំស្ពាយពុនវែកវាថោកបួក ។
របស់បាសកគេប្រគេន ប្រគល់លោកនេនបានលោកភិក្ខុ
ចិញ្ចឹមជីវិតនឹងបាយទឹក បិណ្ឌបាតតែព្រឹកយប់សូត្ររៀន ។
លោកណាត្រឹមត្រូវមិនសូវខុស ស្មៀមស្ងាត់ទៅចុះកុំអន់អៀន
លោកណាមិនចេះកុំវេះវៀន ពាក្យប្រៀនប្រដៅអោយផ្ទើលភ្ញាក់ ។
ព្រះមហាចមពង្សទ្រង់ចំពាក់ ចំពោះធុរះនឹងសាសនា ។
ពីត្រឹមនោះរៀងដរាបមក ដល់ស្រុកគោកធ្លកមានសាវតារ
ប៉ុន្មានរាជ្យហើយមិនដឹងថា ដល់មកករុណាយើងសព្វថ្ងៃ ។
ហេតុនេះលោកសង្ឃប្រុងពិនិត្យ សៀវភៅស្លឹករឹតមានរាល់ដៃ
ផ្ទៀងមើលសិបផ្ទូកវិនិច្ឆ័យ បើនៅសង្ស័យអោយសិក្សា ។
លោកសង្ឃចាស់ខ្ចីគប្បីស្តាប់ ឈ្មោះច្បាប់គន្លងព្រះពុទ្ធដីកា
បង្គំថ្វាយដល់ព្រះករុណា សូមទ្រង់មេត្តាជ្រាបព្រះទ័យ ។
ក្រែងជូនប្រទះពាក្យផ្តាំឆ្គង ពុំត្រូវទំនងក្រិត្យវិន័យ
សូមទានសន្តោសអត់ទោសពៃរ៍ ក្រុញក្រាបសិរសីក្រោមព្រះបាទ ។
ព្រះសង្ឃទាំងអស់ទោះតូចធំ អភ័យទោសខ្ញុំសូមអនុញ្ញាតិ
ពាក្យខ្ញុំមិនមានពោលប្រមាថ សង្ឃជាល្អស្អាតខ្ញុំមិនថា ។
ខ្ញុំពោលតែលោកធ្វើអាក្រក់ បើខ្ញុំកុហកខូចមុសា
ហេតុនោះខ្ញុំសូមបវារណា និជ្ជិតាសង្ខេបតែប៉ុណ្ណោះ ។

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ក្មេងណាប្រាថ្នាបួសធ្វើសង្ឃ      អោយស្ទែងតម្រង់រៀនតម្រេះ
អោយមើលតម្រាប់លោកអ្នកចេះ      កុំដេកតែអេះតិះដៀលគ្នា ។
អ្នកម្តាយឪពុកអោយឈ្មោះ អ៊ូ      ពូជពង្សអំបូរខ្មែរអ្នកជា
អាពុកឈ្មោះ អ៊ុក មានស័ក្តិងារ      ចៅពញាធម្មធារាធ្វើមេស្រុក ។
ក្នុងខែត្រភ្នំពេញឃុំកំបូល      ជាប់ជៅត្រកូលម្ចាស់អង្គ ប៉ុក
អាពុកអ្នកម្តាយឈ្មោះពញា ម៉ុក      គាត់ធ្វើមេស្រុកឃុំស្អានថ្ម ។
អ្នកម្តាយអាពុកបងប្អូនជិត      ជីទួតមួយពិតពូជចិត្តល្អ
ចាស់ទុំផ្សំផ្គុំជាដំណ      បង្កើតខ្ញុំទូលបង្គំ ។
បង្កើតអំពីដើមគំនិត      ភ័យភិតខ្លាចបាបចង់បានបុណ្យ
បានបែកចែងច្បាប់ប្រាប់មហាជន      ៤ ច្បាប់ពីមុនជូនរាជការ ។
បោះពុម្ពសៀវភៅចែកសព្វសាយ      បណ្ណាល័យចាត់ថ្វាយព្រះករុណា
មិនបានថ្វាយផ្ទាល់ដល់ហត្ថា      សូមទ្រង់មេត្តាប្រោសប្រណី ។
ឱនកាយប្រណមសូមអនុញ្ញាតិ      ក្រាបក្រោមព្រះបាទព្រះបារមី
ចែងច្បាប់បរមត្ថអត្ថបាលី      សេចក្តីចែងចប់ម្ល៉េះហើយហោង ។

ព្រះភិរម្យភាសា អ៊ូ ហៅ ឌុំយ

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel